# ការប្រឡងវិញ្ញាសាវិទ្យាល័យ California (CAHSEE)

ច្បាប់រដ្ឋតម្រូវឲ្យសិស្សរៀនទៅក្នុងសាលារៀនសាធារណះប្រចាំ California ប្រឡងវិញ្ញាសាវិទ្យាល័យ (CAHSEE) ឲ្យបានជាប់ដើម្បីទទួលសញ្ញាប័ត្រពីសាលាវិទ្យាល័យ។ ពីមុនការតម្រូវនេះបានចាប់ផ្តើមសំរាប់សិស្សរៀនចប់នៅឆ្នាំ ២០០៤។ នៅខែ កក្កដា ឆ្នាំ ២០០៣ គណះកម្មការក្រសួងអប់រំប្រចាំក្រុងបានធ្វើការពន្យាពេលវេលា សំរាប់ការតម្រូវនេះរហូតដល់ឆ្នាំ ២០០៦ ។ ច្បាប់រដ្ឋបានបោះឆ្នោតយល់ព្រម (ច្បាប់អប់រំលេខ ៦០៨៥០ និង ៦០៨៥១) អនុញ្ញាតិអោយបង្កើត និងប្រតិបត្តិការប្រឡងវិញ្ញាសាវិទ្យាល័យ CAHSEE។ គោលបំណងនៃការប្រឡងវិញ្ញាសាវិទ្យាល័យ CAHSEE នេះដើម្បីពង្រឹងការសិក្សាសិក្សាឲ្យបានសម្រេចនៅតាមសាលាវិទ្យាល័យនិងធ្វើការពិនិត្យមើលឲ្យបានច្បាស់លាស់ថាសិស្សដែលរៀនទទួលបានសញ្ញាប័ត្រពីសាលារៀនអាចធ្វើការបង្ហាញអំពី សមត្ថភាពរបស់ខ្លួនតាមលក្ខណះខ្នាតគំរូរដ្ឋខាងផ្នែក ភាសា អង់គ្លេស និង គណិតសាស្រ្ត ដែលបានចែងឡើងដោយ គណះកម្មការក្រសួងអប់រំរដ្ឋ។

> **ការអនុវត្តន៍របស់ SDCS**
>
> - ខែ ឧសភា ឆ្នាំ ២០០៥: សិស្សរៀននៅសាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ ឆ្នាំ ២០០៦ ចំនួន ៨៣ ភាគរយ និងសិស្សរៀននៅឆ្នាំ ២០០៧ ចំនួន ៧៣ ភាគរយ បានប្រឡងវិញ្ញាសាវិទ្យាល័យ CAHSEEផ្នែក ភាសា អង់គ្លេស បានជាប់។
> - ខែ ឧសភា ឆ្នាំ ២០០៥: សិស្សរៀននៅសាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ ឆ្នាំ ២០០៦ ចំនួន ៨០ ភាគរយ និងសិស្សរៀននៅឆ្នាំ ២០០៧ ចំនួន ៦៩ ភាគរយ បានប្រឡងវិញ្ញាសាវិទ្យាល័យ CAHSEEផ្នែក គណិតសាស្រ្ត បានជាប់។

សិស្សដែលប្រឡងវិញ្ញាសាវិទ្យាល័យ CAHSEE មិនបានជាប់ ពេលរៀននៅថ្នាក់ទីដប់ អាចមានឱកាសធ្វើការប្រឡងឡើងវិញចំនួន ពីរដង ពេលចូលរៀនថ្នាក់ទី ដប់មួយ និងមានឱកាសធ្វើការប្រឡងឡើងវិញចំនួន បីដង ពេលចូលរៀនថ្នាក់ទី ដប់ពីរ។ សិស្សប្រឡងតែមុខវិជ្ជាដែលមិនបានជាប់ប៉ុណ្ណោះ។ បន្ថែមច្បាប់តម្រូវអោយសាលារៀនប្រចាំក្រុងផ្តល់ការបង្រៀនបន្ថែមអោយសមស្មើនឹងខ្នាតមាតិការការសិក្សាផ្នែករដ្ឋ ចំពោះសិស្សដែលប្រឡងវិញ្ញាសាវិទ្យាល័យមិនបានជាប់។ សាលារៀនប្រចាំទីក្រុងសាន់ឌីអេហ្គោផ្តល់ការបំរើទាំងនេះនៅតាមថ្នាក់របស់សិស្សរៀនជាធម្មតា និងក្រោយពេលសិស្សចេញទៅផ្ទះ ព្រមទាំងកម្មវិធីសិក្សានារដូវក្តៅ។

## តើវិញ្ញាសារប្រឡង CAHSEE ជាអ្វី?

វិញ្ញាសារប្រឡង CAHSEE បែងចែកចេញជា ពីរផ្នែក: ភាសា អង់គ្លេស និងគណិតសាស្រ្ត។ សំនួរទាំងនេះបញ្ជាក់អំពី ខ្នាតមាតិការពិសេសដែលគណះកម្មការពិនិត្យមើលការប្រឡងវិញ្ញាសាវិទ្យាល័យ ដែលចាត់តាំងឡើងដោយ អគ្គស្នងការអប់រំបង្រៀនសាធារណះ ដែលមានអារម្មណ៏ថា សិស្សដែលទទួលសញ្ញាប័ត្រពីសាលាវិទ្យាល័យត្រូវតែមានជំនាញការសិក្សាខ្ពស់។ ការប្រឡងវិញ្ញាសារ CAHSEE ខាងផ្នែកភាសារអង់គ្លេស បញ្ជាក់អំពី ខ្នាតមាតិការនៃការសិក្សាដល់ថ្នាក់ទី ១០។ ការប្រឡងវិញ្ញាសារទាំងនោះមានចម្លើយសំរាប់សិស្សជ្រើសរើស និងកិច្ចការដែលសិស្សត្រូវសរសេរផងដែរ។ ការប្រឡងខាងផ្នែក រៀនអាន មានដូចជា ពាក្យពេជ្ជន៍, ពត៏មានស្តីអំពីការរៀនអាន, ព្រមទាំងរៀនអក្សរសាស្រ្ត។ ការប្រឡងខាងផ្នែកគណិតសាស្រ្ត បញ្ជាក់អំពីខ្នាតរដ្ឋដែលមានចាប់ពីថ្នាក់ទី ៦ ដល់ ៨ រួមទឹងការសិក្សាវិជ្ជា ពេជគណិត ពាក់កណ្តាលឆ្នាំទីមួយ ។ ការប្រឡងនោះមានចម្លើយសំរាប់សិស្សជ្រើសរើសដែលមានចំនួនលេខ, ពេជគណិត និងមុខងារ, ការវាស់វែង និងលេខាគណិត, និងប្រូបាបីលីតេ ព្រមទាំងស្ថិតិលេខ។

បោះពុម្ពដែលមានការគាំទ្រពីសមាគម Annie E. Casey

ទាក់ទងពត៌មាន: ក្រសួងផ្នែក ពេទ្យ និងសុខភាព (៨៥៨) ៦២៧-៧៥៨០
ការតម្រូវតាមសាធារណះ (៦១៩) ៧២៥-៥៥៧៨
www.sandi.net
reviese 10/03/05

ការបំរើសិស្សជាង ១៣៦០០០នាក់, សាលារៀនប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺជាសាលារៀនប្រចាំក្រុងធំទី ពីរ ក្នុងចំណោមសាលារៀនទាំងអស់នៅក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមានមណ្ឌលចំនួនជាង ២០២ ព្រមទាំងបុគ្គលិកចំនួន ១៤៥០០នាក់ធ្វើការពេញម៉ោង (តំណាងបុគ្គលិកជាង ១៥៨០០នាក់)។ SDCS ពង្រឹងការអប់រំសិស្សតាមជំនាញគោលការអប់រំផ្នែក រៀនអាន, សរសេរ និងគណិតសាស្រ្ត។ សំរាប់សិស្សបុរេដ្ឋាន ដល់ថ្នាក់ទី១២។ ក្រសួងអប់រំប្រចាំក្រុងផ្តាច់ញ៉ាគាំទ្រសាលារៀន និងបង្កើនបរិយាកាសដល់សិស្សសិក្សានៅតាមបន្ទប់រៀនដោយកែប្រែមណ្ឌលសិក្សា និងទទួលប្រភពពត៏មានទូទៅ និងតាមមាតាបិតាសិស្ស, ការទាក់ទងពីលោកគ្រូ-អ្នកគ្រូ និងសហគមន៏តាមរបៀបអប់រំ។

" បេសកកម្មរបស់ក្រសួងអប់រំប្រចាំទីក្រុង សាន់ឌីអេហ្គោ គឺពង្រឹងការសិក្សាសិស្សឲ្យបានសម្រេច ដោយគាំទ្រការបង្រៀនរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងការសិក្សារបស់សិស្សនៅតាមបន្ទប់រៀន។ "